ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**អគ្គលេខាធិការដ្ឋាន**

**ក្រុមលទ្ធកម្ម**

លេខ:០៩/២៦..កសក.អល.កល

## សេចក្តីជូនដំណឹង
## ស្តីពីការអញ្ជើញចូលរួមពិគ្រោះថ្លៃស្តីពីការផ្គត់ផ្គង់គ្រឿងសង្ហារិម ប្រចាំឆ្នាំ២០២៦
## របស់អង្គភាពថវិកា នៃអគ្គលេខាធិការដ្ឋាន

អង្គភាពថវិកា អគ្គលេខាធិការដ្ឋាន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាស ឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា អគ្គលេខាធិការដ្ឋាន នឹងដាក់ឱ្យពិគ្រោះថ្លៃជាសាធារណៈដើម្បីជ្រើសរើសទទួលអ្នកផ្គត់ផ្គង់គ្រឿងសង្ហារិម ប្រចាំឆ្នាំ២០២៦ របស់អង្គភាពថវិកា នៃអគ្គលេខាធិការដ្ឋាន។

អង្គភាពថវិកា អគ្គលេខាធិការដ្ឋាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំឯកសារសម្រាប់ ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមពិគ្រោះថ្លៃ និងមានដាក់លក់នៅក្រុមលទ្ធកម្ម របស់អង្គភាពថវិកា នៃអគ្គលេខាធិការដ្ឋាន ដែលមានអាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី..១០..ខែ..មីនា.....ឆ្នាំ២០២៦ តទៅរៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទាក់ទងលេខ០៦០ ២១ ២១ ៨៣)។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនក្រុមលទ្ធកម្ម របស់អង្គភាពថវិកា នៃអគ្គលេខាធិការដ្ឋាន យ៉ាងយូរបំផុតត្រឹមថ្ងៃទី...២៥......ខែ..មីនា....ឆ្នាំ២០២៦ វេលាម៉ោង...០៩:៣០.....។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមអាសយដ្ឋាន ខាងលើ វេលាម៉ោង...០៩:៣០'... ថ្ងៃទី...២៥.....ខែ..មីនា..ឆ្នាំ២០២៦។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្ម របស់អង្គភាពថវិកា នៃអគ្គលេខាធិការដ្ឋាន ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ។

ថ្ងៃ..ចន្ទ ៦កើត.......ខែ..ផល្គុន.ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី...៩.......ខែ..មីនា... ឆ្នាំ២០២៦

**អគ្គលេខាធិការ**

**និងជាប្រធានក្រុមលទ្ធកម្ម**

**បណ្ឌិត សរ ចិត្រា**

**ចម្លងជូន:**

- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៣ ០០៨ អ៊ីមែល: info@maff.gov.kh
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 723 008 , Email: info@maff.gov.kh , Website: http://www.maff.gov.kh